www.kidworship.kr

# ចំណងជើង៖ ការរស់ពីសុគតឡើងវិញ



146Page

Narration បន្ទាប់ពីព្រះយេស៊ូទ្រង់បានសុគតនៅលើឈើឆ្កាង
សិស្សរបស់ទ្រង់និងពួកអ្នកដែលបានដើរតាមព្រះយេស៊ូ ពួកគេបានមានទុក្ខព្រួយយ៉ាងខ្លាំង។
ទន្ទឹមនឹងនោះដែរ មហាបូជាចារ្យនៃសាសន៍រ៉ូម និងមេដឹកនាំនៅក្នុងព្រះវិហារបានចងចាំនូវអ្វី
ដែលព្រះយេស៊ូទ្រង់បានមានព្រះបន្ទូល ពីការសុគតរបស់ទ្រង់
និងការរស់ឡើងវិញរបស់ព្រះអង្គនៅបីថ្ងៃក្រោយ។
ដូច្នេះពួកគេបានបញ្ជាឲ្យពួកទាហានបិទច្រកផ្នូររបស់ព្រះយេស៊ូ
ដោយរមៀលដុំថ្មយ៉ាងធំដាក់បិទនៅខាងមុខផ្នូរ
ហើយឲ្យពួកទាហានរងចាំមើលទាំងយប់ទាំងថ្ងៃ។



147Page

Narration នៅពេលព្រឹកព្រលឹមស្រាងៗ នៃថ្ងៃទីបីបន្ទាប់ពីព្រះយេស៊ូទ្រង់បានសុគត
នាងម៉ារីជាអ្នកស្រុកម៉ាដាឡា, នាងម៉ារីជាម្ដាយរបស់យ៉ាកុប និងនាងសាឡូមេ
បានទិញគ្រឿងក្រអូបយកទៅអប់ព្រះសពរបស់ព្រះយេស៊ូ។
ពួកគេបានធ្វើដំណើរទៅឯផ្នូររបស់ព្រះយេស៊ូ
ប៉ុន្តែនៅពេលដែលពួកគេបានទៅដល់ពួកគេបានឃើញដុំថ្មដ៏ធំនោះ បានរមៀលចេញពីផ្នូរ
ហើយផ្នូរគឺនៅទទេ មិនឃើញព្រះសពរបស់ព្រះយេស៊ូនៅទីនោះឡើយ។
ស្ត្រីទាំងអស់នោះមិនដឹងពួកគេត្រូវធ្វើយ៉ាងណាឡើយ
នៅពេលនោះមានទេវតាបានលេចឯពួកគេក្នុងសំលៀកបំពាក់ស
នៅកន្លែងដាក់ព្រះសពហើយមានបន្ទូលថា៖

ទេវតា សូមកុំភ័យអី អ្នកបានឃើញព្រះយេស៊ូត្រូវឆ្កាង
ប៉ុន្តែព្រះជាម្ចាស់បានប្រោសឲ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញហើយ។



148Page

Narration ស្ត្រីទាំងនោះបាននាំគ្នារត់ចេញពីផ្នូរ
ហើយបានយកដំណឹងល្អនេះទៅប្រាប់មនុស្សម្នាឯទៀត
ប៉ុន្តែនៅពេលដែលនាងកំពុងតែរត់ចេញទៅក្រៅនាងបានជួបនឹងបុរសម្នាក់
នោះគឺព្រះយេស៊ូ។ ស្ត្រីទាំងនោះបាននាំគ្នាឱនក្បាលចុះទៀបនឹងព្រះបាទាទ្រង់
ហើយថ្វាយបង្គំព្រះយេស៊ូ។

ព្រះយេស៊ូ ចូរអ្នកទៅប្រាប់មនុស្សគ្រប់គ្នាពីការដែលអ្នកបានឃើញ
ហើយនៅពេលបន្តិចទៀតខ្ញុំនឹងទៅជួបពួកគេនៅកាលីឡេ។



149Page

Narration នៅពេលល្ងាចពួកសិស្សបាននាំគ្នាមកជួបជុំគ្នានៅក្នុងក្រុងយេរូសាឡឹម។
ពួកគេបានចាក់សោទ្វារបន្ទប់ ព្រោះពួកគេខ្លាចពួកទាហានមកចាប់ខ្លួនរបស់ពួកគេ។
នៅពេលនោះព្រះយេស៊ូទ្រង់បានលេចមកចំពោះមុខពួកសិស្សទាំងអស់។


150Page

**ព្រះយេស៊ូ** សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!

**Narration** ពួកគេភ័យតក់ស្លុតជាខ្លាំង ព្រោះស្មានថាខ្មោចលង
ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកគេថា៖

**ព្រះយេស៊ូ** ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តដូច្នេះ? ម្ដេចក៏អ្នករាល់គ្នានៅសង្ស័យបែបនេះ?
ចូរមើលមកដៃនិងជើងរបស់ខ្ញុំ ហើយស្ទាបមើលចុះ ដ្បិតខ្មោចគ្មានសាច់គ្មានឆ្អឹង
ដូចខ្ញុំទេ។

**Narration** ទីបំផុតពួកសិស្សបានជឿថាព្រះយេស៊ូពិតជាមានព្រះជន្មរស់ពីសុគតឡើងវិញមែន។
ពួកគេសប្បាយក្រៃលែង នៅពេលដែលពួកគេបានឃើញទ្រង់ ហើយពួកគេបានលុតជង្គង់
និងថ្វាយបង្គំទ្រង់។
ព្រះយេស៊ូដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ទ្រង់បានសុគតនៅលើឈើឆ្កាង
ដើម្បីសង្គ្រោះពិភពលោកឲ្យរួចពីអំពើបាប ប៉ុន្តែទ្រង់មិនបានសុគតរហូតនោះទេ
គឺបីថ្ងៃក្រោយទ្រង់បានមានព្រះជន្មរស់ឡើងវិញ។

---

**Narration** ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ថា៖

**ព្រះយេស៊ូ** ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក
ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់ចុះ។
អ្នកណាជឿហើយត្រូវធ្វើពិធីបុណ្យជ្រមុជទឹកក្នុងព្រះនាម ព្រះវរបិតា ព្រះរាជបុត្រា
និងព្រះវិញ្ញាណបរិសុទ្ធ។ ព្រមទាំងបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដី
ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង។ ហើយមើល៎!
ខ្ញុំនឹងនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃដែរ រហូតដល់បំផុតកាល។

**Narration** ព្រះយេស៊ូបានសន្យាថា ទ្រង់នឹងយាងមកពីស្ថានបរមសុខជាថ្មីម្ដងទៀត
ដើម្បីវិនិច្ឆ័យទោសមនុស្សនៅលើផែនដី។